1 .

# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៣៣

លេខៈ ២៤៨

ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០២ **នាមនាមប្រជារាស្ត្រខ្មែរ**

**សាលដីកា** **តុលាការកំពូល**

លេខៈ ២១០ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤

ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៊ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ជីវ | កេង | ជាចៅក្រម |
| ៣-លោក | យស់ | សូខឿន | ជាចៅក្រមរបាយការណ៍ |
| ៤-លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៥-លោក | យូរ | ឧត្តរា | ជាចៅក្រម |

**ក្រឡាបញ្ជី**

កញ្ញា សេន សុខា

**តំណាងមហាអយ្យការ**

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៣០ "ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៩៤ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រាជ :

ដើមចោទឈ្មោះ **ឆាង ឆេន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរអភិបាលស្រុកអង្គរបុរី ទីលំនៅសព្វថ្ងៃភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះនាង ម៉ុស "ស" ម្តាយឈ្មោះណៅ ធុន"ស"ប្រពន្ធឈ្មោះស៊ិន ចាន់ថន កូន៤នាក់ ។

ចុងចម្លើយឈ្មោះ **ផាន់ ទុច** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ កំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ ផិន ផាន់ "ស" ម្តាយឈ្មោះសុខ សួន "ស" ប្តីឈ្មោះជា ឈៀង មានកូន០៦នាក់ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដីត្រពាំងទឹកទំហំ ៦០ម x ៣២ម .

**បណ្តឹងតប** : ទាមទារយកស្រះទឹកវិញ .

បានឃើញបណ្តឹងសាទុក្ខលេខ ១៩៩ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះ

នាង សិន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣០"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៨ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះនាង សិន ចុះថ្ងៃទី០៣-៥-២០០០ បានប្តឹងសុំទាមទារដីត្រពាំងទឹកទំហំ ៦០ម គុណ ៣២ម ពីចុងចម្លើយឈ្មោះផាន់ ទន់ នៅភូមិកំពង់ជ្រៃ ស្រុកទ្រាំង ខេត្តតាកែវ ដោយហេតុថា ដីនេះខ្លួនបានគ្រប់គ្រងរស់នៅមុនគេ ចាប់តាំងពីឆ្នាំ១៩៨១ មក តែដល់ឆ្នាំ១៩៨៥ ខ្លួនបានជីកស្តារត្រពាំងទឹកនោះ ស្រាប់តែចុងចម្លើយមកជំទាស់ ហើយពេលនោះ អាជ្ញាធរឃុំ ក៏បានចុះពិនិត្យកន្លែងទំនាស់នោះ ឃើញថា ពុំមានឃើញប៉ះពាល់អ្វីដល់ចុងចម្លើយទេ ហើយរដ្ឋអំណាចឃុំក៏ឱ្យខ្លួនជីកបន្តទៅទៀត ។

តាមពាក្យបណ្តឹងតបចុះថ្ងៃទី៩-៤-២០០០ របស់ចុងចម្លើយឈ្មោះផាន់ ទន់ បានអះអាងថា នៅឆ្នាំ១៩៨២ ដីត្រពាំងទឹកទំហំ ៨០អា ស្ថិតនៅខាងក្រោយផ្ទះខ្លួន ហើយខ្លួនបានគ្រប់គ្រងដីត្រពាំងនោះតាំងពីឆ្នាំ១៩៨២មកម្ល៉េះ ព្រមទាំងបានឱ្យកូនក្មួយរបស់ខ្លួនជីកស្តារ ជីរៅ ដើម្បីយកទឹកប្រើប្រាស់ និងដាំដំណាំជុំវិញត្រពាំងនោះជាច្រើនដើម ដូចជា ដើមដូង .ប្រេងខ្យល់.ឫស្សី.ខ្វិត. ស្វាយ.ត្របែក .ព្រីង. អំពិលបារាំង.ចេក និងងដើមត្នោតជាដើម ពេលនោះ ពុំឃើញមាននរណាមកជំទាស់តវ៉ាពីត្រពាំងនេះឡើយ ។ស្រាប់តែនៅថ្ងៃទី៧-៤-២០០០ ឈ្មោះនាង សិន បានបញ្ជាក់ប៉េអឹម ២នាក់ ឱ្យមកកាត់ខ្សែលួសរបងត្រពាំងរបស់ខ្លួនចេញ ហើយបានបោះបង្គោលវាតទីយកដីត្រពាំងខ្លួនអស់ទំហំ ៣០ម ពេលនោះខ្លួនក៏បានប្តឹងទៅតុលាការខេត្តតាកែវភ្លាមតែម្តង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣៨ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៣-៥-២០០០ របស់ដើមចោទឈ្មោះនាង សិន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ប្រគល់ដីត្រពាំងទឹកទំហំពីខាងត្បូង ២៣ម .ពីខាងជើង២៥ម.៥ បណ្តោយ ៩០ម.៦០ ស្ថិតនៅភូមិកំពង់ជ្រៃ ឃុំស្នោង ស្រុកទ្រាំង ខេត្តតាកែវ ឱ្យទៅឈ្មោះនាង សិន ជាដើមចោទ កាន់កាប់ប្រើប្រាស់ចាប់ពីពេលនេះតទៅ ។ កាលបើផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យយាយផាន់ ទន់ ជាចុងចំលើយ លើងកូនឈើមានទាំងប៉ុន្មាន លើភ្លឺត្រពាំងជាចំណែករបស់នាងសិនចេញឱ្យអស់ ។

៣-ប្រាក់ប្រដាប់ក្តី ៧.០០០៛ ដើមចោទបានបង់រួចហើយ កាលបើផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចំលើយបង់ប្រាក់នេះ សងទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចំលើយ បង់ប្រាក់ពន្ធសមាមាត្រស្មើ១% លើតំលៃដីទំនាស់ ប្រាក់នេះ ៨០% បង់ចូលថវិការដ្ឋ និង២០% សំរាប់

រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់កំណត់១៥ថ្ងៃ និង ៦០ថ្ងៃទៀត សំរាប់ប្តឹងឧទ្ធរណ៍ គិតចាប់តាំងពីថ្ងៃទទួលដំណឹងពីសាលក្រមនេះ ។

បានឃើញបណ្តឹងទាស់លេខ ៧០ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់ឈ្មោះផាន់ទន់ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៣៨ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការខេត្តតាកែវ ត្រង់ចំណុច សុំឱ្យតុលាការខេត្តតាកែវ ជំនុំជំរះសាជាថ្មីឡើងវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៣ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៣-០៥-២០០០ របស់ដើមចោទឈ្មោះ នាងស៊ិន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ដីត្រពាំងទឹក ទំហំទទឹងពីខាងត្បូង ២៣ម X ទទឹងពីខាងជើង២៥ម.៥ បណ្តោយ៥០ម.៦០ ស្ថិតនៅពីខាងផ្ទះលោក នាង ស៊ិន ភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ប្រគល់ឱ្យទៅឈ្មោះនាង ស៊ិន ជាដើមចោទកាន់កាប់ប្រើប្រាស់ចាប់ពីពេលនេះតទៅ តាមបញ្ញត្តិមាត្រា១៧និង៧៤នៃច្បាប់ភូមិបាល ។ កាលបើផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យយាយផាន់ ទន់ ជាចុងចំលើយ លើងកូនឈើមានទាំងប៉ុន្មានលើភ្លឺត្រពាំងជាចំណែករបស់នាងស៊ិន ចេញឱ្យអស់ ។

៣-ប្រាក់ប្រដាប់ក្តី៧.០០០រៀល ដើមចោទបានបង់រួចហើយ កាលបើផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចំលើយ បង់ប្រាក់នេះសងទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ពន្ធសមាមាត្រស្មើ១% លើតំលៃដីទំនាស់ ប្រាក់នេះ ៨០% បង់ចូលថវិការដ្ឋ និង ២០% សំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍ កំណត់៦០ថ្ងៃ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០ របស់ឈ្មោះផាន់ ទន់ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៤៣ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣០"ក"ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣-១២-២០០០ របស់ចុងចំលើយឈ្មោះផាន់ ទន់ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធ សាលក្រមរដ្ឋប្បវេណីលេខ ៤៣ ចុះថ្ងៃទី០៥-១២-២០០០ របស់

តុលាការខេត្តតាកែវ ចោលជាអសារបង់តទៅ ។

៣-ប្រគល់ដីត្រពាំងទឹកទំហំទទឹងពីខាងត្បូង ២៣ម X ទទឹងពីខាងជើង២៥ម៥ បណ្តោយ ៥០ម៦០ ស្ថិតនៅពីខាងក្រោយផ្ទះលោកនាង សិន ភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ប្រគល់ឱ្យទៅឈ្មោះផាន់ ទន់ ជាចុងចំលើយ កាន់កាប់ប្រើប្រាស់ជាកម្មសិទ្ធិស្របច្បាប់ ចាប់ពីពេលនេះតទៅ ។ តាមបញ្ញត្តិមាត្រា១៧ និង ៧៤ នៃច្បាប់ភូមិបាល ។

៤-កាត់យកប្រាក់ប្រដាប់ក្តី ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍ឈ្មោះផាន់ទន់ បានបង់ទុករួចហើយ ប្រាក់បែងចែកសំរាប់ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ្រឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ ហិបប្រាក់ ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ចំនួន ១៣.០០០៛ ។

កាលបើហួសបណ្តឹងសាទុក្ខ ត្រូវបង្គាប់ឱ្យឈ្មោះនាង សិន បង់ពន្ធសមាមាត្រមួយភាគរយ (១%)លើតម្លៃដីទំនាស់ជាក់ស្តែង ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និងសំរាប់ជារង្វាន់ ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកសិទ្ធិឱ្យ ប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៩៩ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះ នាង សិន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣០"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះនាង សិន ។

បានឃើញសារណាតបចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះផាន់ ទន់ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : សាលាឧទ្ធរណ៍សំរេចសេចក្តី មកនេះ ពុំត្រឹមត្រូវទេ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះនាង សិន នាពេលសវនាការថា :ដីស្រែនេះជារបស់សាលា រៀនចិន លុះដល់ឆ្នាំ១៩៨១ ខ្លួនបានសង់ផ្ទះនៅ ដោយស្រះនេះនៅខាងក្រោយផ្ទះខ្លួន ក្រោយមក ខ្លួនសង់រោងម៉ាស៊ីនរួមគ្នា ដោយឱ្យប្តីអ្នកស្រី ផាន់ ទន់ ជាអ្នកមើលជួសជុលម៉ាស៊ីន លុះក្រោយ មកទៀតអ្នកស្រី ផាន់ ទន់ បានសុំខ្លួនមករស់នៅក្បែររោងម៉ាស៊ីននេះ ដោយគាត់ជាអ្នកជួសជុល ម៉ាស៊ីន ខ្លួនក៏អនុញ្ញាតិ ។ លុះក្រោយមកទៀត ដោយខ្លួនមិនអាចគ្រប់គ្រងរោងម៉ាស៊ីនបាន ដោយ រវល់ធ្វើការ ខ្លួនក៏សុំភាគហ៊ុនមកវិញ ។ឯទីតាំងដីនៅដដែល ហើយចំពោះឬងដីនេះ គឺគាត់បានស៊ី គ្រលំ លួចធ្វើប័ណ្ណកម្មសិទ្ធិ ហើយរឿងនេះ ខ្លួនបានរាយការណ៍ប្រាប់ឃុំជាហូរហែរ គាត់បានកំទេច របងរបស់ខ្លួនចោលអស់ ដោយខ្លួនពុំមានប្រតិកម្មអ្វីទេ ។ ឯសាលាឧទ្ធរណ៍ថា ខ្លួនអស់សិទ្ធិប្រើ

ប្រាស់ គឺមិនត្រឹមត្រូវទេ ហើយស្រះទឹកនេះ ខ្លួនជាអ្នកស្តារ ចំពោះបញ្ហាដើមដូងពីរដើម ខ្លួនបានប្តឹងទៅឃុំដែរ ។ ខ្លួនសុំទាមទារតែស្រះទឹក នៅខាងក្រោយផ្ទះរបស់ខ្លួនទេ ។

បានស្តាប់ចំលើយរបស់ឈ្មោះ ផាន់ ទន់ នាពេលសវនាការថា : ដីនេះពីមុនខ្លួនបានសុំគាត់រស់នៅមែន តែការកាន់កាប់ដីត្រពាំងទឹក និងដីភូមិ គឺខ្លួនជាអ្នកគ្រប់គ្រង ដោយដាំដំណាំ និងបានស្តារយកស្រះទឹកទៀតផង ។ លុះដល់ឆ្នាំ១៩៨៦ គាត់បានជីកស្រះ តែខ្លួនប្តឹងមិនឱ្យជីក គាត់ក៏បាត់ខ្លួន ទើបតែឆ្នាំ២០០០ ទើបគាត់យកនគរបាលមកព័ទ្ធកាត់ត្រពាំងរបស់ខ្លួនយក ពេលនោះកូនខ្លួនក៏បានប្តឹងសុំផ្អាកសិន ព្រោះកំពុងតែរវល់ ហើយខ្លួនក៏បានដាំដើមដូងនៅលើដីរបស់ខ្លួនដែរ ឯដីទំនាស់នេះ ក៏ខ្លួនមិនហ៊ានធ្វើអ្វីទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៩៩ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០២ របស់លោក នាង សិន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាម មាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីត្រពាំងទឹក ទំនាស់ទំហំពីខាងត្បូង២៣ម x និងពីខាងជើង ២៥ម,៥ បណ្តោយ៥០ម,៦០ស្ថិតនៅខាងក្រោយផ្ទះលោកនាងសិន ឱ្យទៅឈ្មោះផាន់ ទន់ កាន់កាប់ប្រើប្រាស់ជាកម្មសិទ្ធិនោះ មិនត្រឹមត្រូវទេ ពីព្រោះដីត្រពាំងទឹកនេះ គូភាគីបានទទួលស្គាល់តាំងពីឆ្នាំ១៩៨២ ឬ៨៣ មកថា បានកាន់កាប់រួមគ្នា ហើយតាមការបញ្ជាក់របស់លោកអភិបាលស្រុកទ្រាំងចុះថ្ងៃទី២០-៤-២០០០ ថា ដីស្រះត្រពាំងទឹកនេះ ជាត្រពាំងទឹកសាធារណៈ តាំងពីដើមមក មិនទាន់មានការបែងចែកឱ្យអ្នកណាម្នាក់ឡើយ ហើយក៏ពុំមានចុះក្នុងបញ្ជីសារពើភ័ណ្ឌដែរ គប្បីបែងចែកគ្នា តាមចំណែកពីខាងក្រោយផ្ទះរៀងៗខ្លួន ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំអាងថា ដីទំនាស់ចុងក្រោយ ដើមចោទមិនបានកាន់កាប់ទេ មានតែចុងចំលើយកាន់កាប់ជាប់រហូតមក នោះជាការភ័ន្តច្រឡំ ពីព្រោះថា ដើមចោទ បានជីកស្តារយកទឹកប្រើប្រាស់រហូតមកទល់បច្ចុប្បន្ននេះ បានទាំងធ្វើរបងតាមការបែងចែកពីអាជ្ញាធរមូលដ្ឋាន ដើម្បីការពារទំនាស់ តែត្រូវចុងចម្លើយទៅរុះរើចោលអស់ ។

- យល់ឃើញថា ការដែលចុងចម្លើយដាំដុះដំណាំនានាលើភ្លឺត្រពាំងក្រោយផ្ទះ ដើមចោទនោះ គឺធ្វើឡើងក្នុងពេលមានទំនាស់ និង ត្រូវបានដើមចោទប្តឹងទៅរដ្ឋអំណាចជាបន្តបន្ទាប់ ។ ដូច្នេះចុងចម្លើយ ពុំអាចមានសិទ្ធិលើត្រពាំងនេះ ដោយការដាំដុះរបស់ខ្លួនបានឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៣០"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីទំនោះចុងក្រោយ**

១-ទទួលបណ្តឹងសាទុក្ខលេខ១៩៩ ចុះថ្ងៃទី២៩ខែឧសភាឆ្នាំ២០០២ របស់លោកនាង ស៊ិន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៣០"ក" ចុះថ្ងៃទ១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៨ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ២០០២ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោកនាង ស៊ិន បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រីផាន់ ទន់ សងប្រាក់ ១៩.០០០៛ នេះទៅលោកនាង ស៊ិន វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ។